# one វិធានការសាមញ្ញ

## បញ្ឈប់ការរំលោភបំពានប្រើប្រាស់សារធាតុអូភីអូត OPIOID

លោកអ្នកអាចជាមនុស្សម្នាក់ដែលរក្សាសុវត្ថិភាពគ្រួសាររបស់អ្នក។

វាចាប់ផ្តើមពីវិធានការទីមួយ។ សកម្មភាពមួយនៃភាពក្លាហាន។ ការសន្ទនាស្មោះត្រង់។

នៅពេលនិយាយអំពីការការពារពីការប្រើសារធាតុអូភីអូត opioid មិនត្រឹមត្រូវនោះ លោកអ្នកអាចធ្វើឱ្យមានភាពខុសគ្នា។ សូមពិភាក្សាជាមួយមនុស្សជាទីស្រលាញ់របស់អ្នក ហើយចែករំលែកការពិត។

ឥឡូវនេះ ថ្នាំ **Opioids** ជាមូលហេតុចម្បងមួយក្នុងចំណោមមូលហេតុនានានៃការស្លាប់ដែលទាក់ទងនឹងការរងរបួសនៅរដ្ឋវ៉ាស៊ីនតោន **Washington** ។ មនុស្សកាន់តែច្រើនស្លាប់ពីការប្រើថ្នាំហួសកម្រិតកំណត់ច្រើនជាងគ្រោះថ្នាក់រថយន្ត។[1]

ការប្រើសារធាតុអូភីអូត **opioid** មិនត្រឹមត្រូវ **75** ភាគរយ ចាប់ផ្តើមពីការប្រើប្រាស់ថ្នាំដែលមិនបានចេញវេជ្ជបញ្ជាឱ្យពួកគេ - ជាធម្មតាពួកគេយកថ្នាំយកពីមិត្តភក្តិ ឬសមាជិកគ្រួសារ។[2]

ក្មេងៗ **50** ភាគរយទំនងជាប្រើថ្នាំតិចជាង នៅពេលមាតាបិតាប្រាប់ពួកគេអំពីគ្រោះថ្នាក់។[2]

## បញ្ហាទាក់ទងនឹងឥទ្ធិពលថ្នាំរបស់អ្នក

ចាក់សោរថ្នាំរបស់អ្នក។

ពិភាក្សាជាមួយមនុស្សជាទីស្រលាញ់របស់អ្នកអំពីហានិភ័យនៃការរំលោភបំពានប្រើសារធាតុអូភីអូត opioid។

ពិភាក្សាជាមួយវេជ្ជបណ្ឌិតរបស់អ្នកអំពីមធ្យោបាយផ្សេងៗដើម្បីគ្រប់គ្រងការឈឺចាប់។ លើកទឹកចិត្តមនុស្សជាទីស្រលាញ់របស់អ្នក ដើម្បីអនុវត្តដូចគ្នា។

បោះចោលថ្នាំដែលមិនបានប្រើដោយសុវត្ថិភាព នៅឯកម្មវិធីទទួលរបស់ប្រើឬមិនប្រើត្រឡប់មកវិញ ដែលស្ថិតនៅជិតលោកអ្នក។សូមស្វែងរកព័ត៌មានតាមរិបសាយ **TakeBackYourMeds.org**.

Washington State Health Care Authority

## យល់ដឹងអំពីការពិត

### តើសារធាតុ Opioid ជាអ្វី?

សារធាតុអូភីអូត Opioids
គឺជាប្រភេទថ្នាំផាក់លាក់
ដែលជាទូទៅគេប្រើ
ដើម្បីបន្ថយការឈឺចាប់។

ហេរ៉ូអ៊ីនខុសច្បាប់ គឺជាសារធាតុអូភីអូត
opioid ជាថ្នាំបំបាត់ការឈឺចាប់ជាច្រើន
ដែលវេជ្ជបណ្ឌិតបានចេញវេជ្ជបញ្ជា។

សារធាតុអូភីអូត Opioids អាចមាន
ផលប៉ះពាល់អវិជ្ជមានដល់ចំណុចកណ្តាល
នៃប្រព័ន្ធសរសៃខួរក្បាល។
តាមពេលវេលាកន្លងទៅ អ្នកប្រើអាច
ត្រូវការកាន់តែច្រើនឡើងៗ
ដែលធ្វើឱ្យគ្រឿងញៀនទាំងនេះ
កាន់តែញៀនខ្លាំងឡើង។[4]

## ជម្រើសបន្ថយការឈឺចាប់ផ្សេងទៀត

ប្រសិនបើលោកអ្នកត្រូវបានចេញ
វេជ្ជបញ្ជាឱសថអូភីអូត opioid សូម
ពិភាក្សាជាមួយវេជ្ជបណ្ឌិតរបស់អ្នក
អំពីជម្រើសផ្សេងទៀត។

ពិភាក្សាជាមួយអ្នកផ្តល់សេវាសុខភាព
ខាងអាកប្បកិរិយាអំពីយុទ្ធសាស្ត្រនានា
ដែលអាចជួយគ្រប់គ្រងភាពតានតឹង។[3]

សាកល្បងការព្យាបាលដោយចលនា
ឬការព្យាបាលផ្សេងទៀត
ដូចជាការចាក់ម្ជុលវិទ្យាសាស្ត្រ
ឬម៉ាស្សា។[3]

## សិក្សាបន្ថែមទៀតតាមវិបសាយ

# GetTheFactsRx.com

ប្រភពឯកសារ៖ [1]ក្រសួងសុខាភិបាលរដ្ឋវ៉ាស៊ីនតោន (Washington State Department of Health), [2]រដ្ឋបាលសេវាការរំលោភបំពានសារធាតុនិងសុខភាពផ្លូវចិត្ត, [3]មជ្ឈមណ្ឌលត្រួតពិនិត្យនិងបង្ការជំងឺឆ្លង [4]វិទ្យាស្ថានជាតិស្តីពីការរំលោភបំពានគ្រឿងញៀនចំពោះមនុស្សវ័យជំទង់

For more information:
kingcounty.gov/overdose

King County

Washington State
Health Care Authority